01652356

E004/2/18

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អវតក-អជសង/អជតក

ភាគីដាក់ឯកសារ៖ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / 07 / 2020
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានតំណាងតាមផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/០២**

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គឹមសួន
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

នៅចំពោះមុខ៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម C.N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

០០៤/២/០៧-០៩-២០០៩-អវតក-អជសង/អជតក

ផ្ញើជូន៖

| | |
|---|---|
| **សហព្រះរាជអាជ្ញា** | **សហមេធាវីការពារក្តី អៀង សារី** |
| ជា លាង | អ៊ុំ លុជ្ជ |
| Brenda HOLLIS | Richard ROGERS<br>Göran SLUITER |

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Laure DESFORGES
Isabelle DURAND
គីម ម៉េងឃី
Lyma NGUYEN
ស៊ិន សុវ័ន

# I. សេចក្តីផ្តើម

1. ដោយពិចារណាដល់បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") និងការដាក់ជូនបណ្តឹងសាទុក្ខនេះដល់ភាគីនានា តាមរយៈប្រព័ន្ធជូនដំណឹងនៅក្នុងសំណុំរឿង ដែលបានចាត់ជាសំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជតក (០៤)[1] ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ ស.ព.អ[2] និង ការឆ្លើយតបរបស់ ស.ព.អ[3] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ពាក់ព័ន្ធនឹងតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ សំណើនេះត្រូវបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") ដោយហេតុថាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") មិនអាចចូលពិនិត្យមើលសំណុំរឿងបាន។

2. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវលើកឡើងនូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងម្តងហើយម្តងទៀតទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសវនាការ សិទ្ធិមានតំណាង សិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ និងសិទ្ធិទទួលបានតម្លាភាព និងការផ្សព្វផ្សាយជាសាធារណៈនូវកិច្ចដំណើរការនីតិវិធីទាំងនេះ ជូនអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដោយពិចារណាទៅលើភាពមិនប្រាកដប្រជាផ្នែកនីតិវិធីនៅក្នុងសំណុំរឿង ០០៤/២ និងផលប៉ះ

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក ("សំណុំរឿង ០០៤/២") ឯកសារ **E004/2.1** ការចុះបញ្ជីបណ្តឹងសាទុក្ខភ្លាមៗ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ("ដែលជូនដំណឹង*ជាផ្លូវការ*ដល់អង្គជំនុំជម្រះតុលាការកំពូល និងភាគីទាំងអស់អំពីបណ្តឹងសាទុក្ខភ្លាមៗ ដើម្បីធានាថា ការទទួល និង ការដាក់បណ្តឹងសាទុក្ខភ្លាមៗ មិនត្រូវបានពន្យារពេលតទៅទៀតនោះឡើយ")។ សំណុំរឿង ០០៤/២ ឯកសារ **E004/2/1** បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០។

[2] សំណុំរឿង ០០៤/២ ឯកសារ **E004/2/1/1** ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។

[3] សំណុំរឿង ០០៤/២ ឯកសារ **E004/2/1/1/1** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងលិខិតរបស់ អោ អាន ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់លោកស្រី ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០។

ពាល់ជាក់លាក់ទៅលើសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ[4]។ ឯកសារនោះបានរៀបរាប់លម្អិតនូវករណីជាច្រើនដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខមិនទទួលបានការចម្លងជូននូវការដាក់ឯកសារ និងលិខិតប្រាស្រ័យទាក់ទងនានា ពីភាគី ពី អ.ប.ជ និងពីអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ទោះបីឯកសារទាំងនេះពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្តី[5]។ សហមេធាវីនាំមុខសម្តែងការសោកស្តាយថា ការរំលោភបំពានធ្ងន់ធ្ងរ និងដដែលៗទាំងនេះនៅតែបន្តកើតមាន ហើយថា ពុំទាន់មានដំណោះស្រាយច្បាស់លាស់ចំពោះការរំលោភបំពានទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក នៅឡើយទេ។

3. នាពេលនេះ ស្ថានភាពកាន់តែស្មុគ្រស្មាញនៅពេលដែលបញ្ហានានាត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ វិធានផ្ទៃក្នុងកំណត់ថា សហមេធាវីនាំមុខធ្វើជាតំណាងឲ្យក្រុមរួមនៃដើមប

---

[4] សំណុំរឿង 00៤/២ ឯកសារ D359/33 & D360/42 សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង00៤/២ ចុះថ្ងៃទី៣0 ខែមីនា ឆ្នាំ ២0២0 ("សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យ អ.ប.ជ ផ្តល់ការធានា")។

[5] *សូមមើល* សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យ អ.ប.ជ ផ្តល់ការធានា, ទំព័រ ៧-១១។ ជាឧទាហរណ៍ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំបានទទួលសំណៅថតចម្លងលិខិតចុះថ្ងៃទី២៦ និងថ្ងៃទី៣0 ខែធ្នូ ពីសហព្រះរាជអាជ្ញាអន្តរជាតិ និងពី អោ អាន ដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនោះទេ។ សំណុំរឿង 00៤/២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការពន្យារពេល ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់គាត់ ដែលបានដាក់កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២0១៩ (មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារនេះនៅឡើយទេ។ ហេតុដូច្នេះ ការលើកឡើងនេះត្រូវបានសំអាងទៅលើជើងទំព័រយោងលេខ ៦, ទំព័រ ១ នៃបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង 00៤/២ ដោយអនុលោមតាមវិធាន ៨0, ដែលបានដាក់ជូនកាលពីថ្ងៃ១៣ ខែមករា ឆ្នាំ២0២0)។ សំណុំរឿង 00៤/២, ឯកសារ D359/27.1.1, សំណើសុំការបញ្ជាក់បំភ្លឺថា អង្គជំនុំជម្រះសាលាដំបូងពុំទាន់បានទទួលសំណុំរឿង 00៤/២ ស្របតាមផ្លូវច្បាប់នៅឡើយទេ។ នៅក្នុងសំណើមួយផ្សេងសុំបន្ថែមពេលវេលា និងការណែនាំសម្រាប់ការដាក់អញ្ញត្រកម្ម ដោយអនុលោមតាមវិធាន ៨៩, ចុះថ្ងៃទី៣0 ខែធ្នូ ឆ្នាំ២0១៩ (យើងខ្ញុំបានដឹងពីការដាក់ឯកសារនេះ ពីព្រោះវាលេចឡើងនៅក្នុងឧបសម្ពន្ធនៃការដាក់ឯកសារមួយផ្សេងទៀត)។ ស្រដៀងគ្នានេះដែរ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំបានទទួលសំណៅថតចម្លងអ៊ីមែលចុះថ្ងៃទី២១ ខែមករា ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានដាក់ជូនទៅក្រុម អ.ប.ជ, ការិយាល័យរដ្ឋបាល, អោ អាន និងសហព្រះរាជអាជ្ញា ឬអ៊ីមែលចុះថ្ងៃទី១0 ខែកុម្ភៈ ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានដាក់ជូនសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីរបស់ អោ អាន នោះទេ។ សំណុំរឿង 00៤/២, ឯកសារ D359/27.1.2, អ៊ីមែលពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ ការជូនដំណឹងដល់ភាគី ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២0២0។ សំណុំរឿង 00៤/២, ឯកសារ D359/27.1.3, អ៊ីមែលពីលោក លឹម ស៊ុយហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖ សំណើថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២0២0 របស់ ស.ព.អ ចុះថ្ងៃទី១0 ខែកុម្ភៈ ឆ្នាំ២0២0។

ណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលជំនុំជម្រះឡើងទៅ ដែលការពិត មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗពុំមានតួនាទីក្នុងការដាក់សេចក្ដីសន្និដ្ឋានដោយឯកឯង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២[6] ហើយវិធាន ១០៦(៤) នៃវិធានផ្ទៃក្នុងចែងច្បាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតំណាងដោយសហមេធាវីនាំមុខ នៅចំពោះមុខ អ.ជ.ត.ក ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខភ្លាមៗ និងបណ្ដឹងសាទុក្ខជំទាស់នឹងសាលក្រម។ ទោះជាយ៉ាងណាក្ដី បើតាមព័ត៌មានដែលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានគឺថា សហមេធាវីនាំមុខមិនអាចចូលពិនិត្យមើលសំណុំរឿង ០០៤/២ បាន ហើយការិយាល័យរដ្ឋបាលបានជូនដំណឹងថា អាណត្តិការងាររបស់ពួកគេមិនលាតសន្ធឹងដល់សំណុំរឿងនេះទេ[7]។ ហេតុនេះ ដើមបណ្ដឹងរដ្ឋប្បវេណីពុំមានតំណាងផ្លូវច្បាប់ច្បាស់លាស់នៅចំពោះមុខ អ.ជ.ត.ក ដែលត្រូវការពារសិទ្ធិជាសារវ័ន្តរបស់ពួកគេ ទៅលើបញ្ហាសំខាន់ៗដែលកំពុងស្ថិតក្នុងនៅចំពោះអង្គជំនុំជម្រះនាពេលនេះ។

4. ដើម្បីឱ្យមានភាពឆាប់រហ័ស មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំការអនុញ្ញាតដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ចំណែកការបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយឱ្យបានឆាប់តាមដែលអាចធ្វើបាន[8]។

---

[6] *សូមមើល* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ("សំណុំរឿង ០០២") ឯកសារ **E74** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ទំព័រ ៣ (ដែលលើកឡើងថា ការកែប្រែទៅលើវិធានផ្ទៃក្នុង ដែលត្រូវបានធ្វើវិសោធនកម្មចាប់តាំងពីសំណុំរឿង ០០១ មក អនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បែងចែកមុខងារទៅឱ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែ "មេធាវីនីមួយៗ ដែលតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិជាស្វ័យប្រវត្តិនៅចំពោះមុខអង្គជំនុំជម្រះឡើយ")។

[7] អ៊ីមែលពីលោកស្រី Megan Hirst សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ កម្មវត្ថុ៖ សំណើសុំសំណៅថតចម្លងនៃបណ្ដឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយ អ.ជ.ស.ដ, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ [មូលដ្ឋានសំអាងផ្លូវច្បាប់ទី ២] (ដែលលើកឡើងថា "ឋានៈរបស់លោកស្រី Hirst នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ នៅតែមិនទាន់ច្បាស់លាស់នៅឡើយទេ" ហើយលោកស្រី "ពុំមានសិទ្ធិចូលមើលសំណុំរឿង ០០៤/២ ទេ")។

[8] អ៊ីមែលពីលោក វ័ន្ត បញ្ញាណ អ្នកបកប្រែភាសា អង្គភាពបកប្រែភាសា កម្មវត្ថុ៖ ក្របខណ្ឌពេលវេលាដែលបានប៉ាន់ប្រមាណសម្រាប់ការបកប្រែ, ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ [មូលដ្ឋានសំអាងផ្លូវច្បាប់ទី ៣] (ដែលប៉ាន់ប្រមាណថា ប្រសិនបើដាក់ជូនសម្រាប់ការបកប្រែនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ នោះការផ្ដល់ជូននូវការបកប្រែនាពេលនេះ នឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ មុនម៉ោងឈប់សម្រាកពីការងារ)។

## II. ប្រវត្តិនីតិវិធី

5. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ៨ នាក់ បានដាក់សំណើរបស់ខ្លួនស្នើសុំវិធានការចាំបាច់នានារបស់អង្គបុរេជំនុំជម្រះដើម្បីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២[9]។ អ.ប.ជ មិនទាន់បានចេញសេចក្ដីសម្រេចលើសំណើនេះនៅឡើយទេ។

6. នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិដាក់បណ្ដឹងសាទុក្ខភ្លាមៗរបស់គាត់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង[10]។

7. នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ (តែត្រូវបានបោះត្រាដោយមន្ត្រីគ្រប់គ្រងសំណុំរឿង នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០) មេធាវីការពារក្ដី អោ អាន បានឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង[11]។

8. នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់ អោ អាន[12]។

9. នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញអនុស្សរណៈមួយដំណឹងដល់ "ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០៤/២ និង អ.ជ.ត.ក ថា យើងនឹងផ្អាកការចេញសេចក្ដីសម្រេចរបស់យើងលើសំណើនេះ [សំណើរបស់មេធាវីការពារក្ដីចុះថ្ងៃទី១៧ ខែមីនា

---

[9] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យ អ.ប.ជ ផ្ដល់ការធានា។

[10] សំណុំរឿង ០០៤/២, ឯកសារ E004/2/1, បណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០។

[11] សំណុំរឿង ០០៤/២ ឯកសារ E004/2/1/1 ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។

[12] សំណុំរឿង ០០៤/២ ឯកសារ E004/2/1/1/1 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងលិខិតរបស់ អោ អាន ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់លោកស្រី ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០។

ឆ្នាំ២០២០ សុំបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ] ជាបណ្ដោះអាសន្នសិន ដោយរង់ចាំសាលដីកាសម្រេចរបស់ អ.ជ.ត.ក ទៅលើបណ្ដឹងសាទុក្ខភ្លាមៗ"[13]។

## III. ច្បាប់ជាធរមាន

10. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា៖

> ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖
>
> ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ...
>
> [...]
>
> គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធី ...
>
> [...]

11. វិធាន ១២ និង ១៣ នៃវិធានផ្ទៃក្នុង រៀបរាប់លម្អិតអំពីរចនាសម្ព័ន្ធពីរដាច់ពីគ្នា ដែលគ្រប់គ្រងនូវការតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក។

12. វិធាន ១២ នៃវិធានផ្ទៃក្នុងចែងថា៖

---

[13] សំណុំរឿង ០០៤/២ ឯកសារ **D364** អន្ទរណៈពីសហចៅក្រមស៊ើបអង្កេត, កម្មវត្ថុ: សំណើរបស់មេធាវីការពារក្ដី ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ សុំឲ្យបញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងប័ណ្ណសារ–ឯកសារ D363 ("សំណើ") ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ទំព័រ ១។

ការិយាល័យរដ្ឋបាលត្រូវបង្កើតអង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានស្វ័យភាព ពាក់ពន្ធ័នឹងការងារសំខាន់ៗដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។ ការិយាល័យរដ្ឋបាលអាចចុះកិច្ចសន្យាជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ការិយាល័យរដ្ឋបាលក៏ផ្តល់ផងដែរនូវការគាំពារផ្នែករដ្ឋបាលដែលចាំបាច់ ដល់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងគ្រប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

13. វិធាន ១២*ស្ទួនពីរ* (១) នៃវិធានផ្ទៃក្នុងចែងថា "សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវធានាឲ្យមានការរៀបចំការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយប្រសិទ្ធភាព ចាប់ពីដំណាក់កាលជំនុំជម្រះ*ឡើងទៅ*ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក" (គូសបញ្ជាក់បន្ថែម)។ វិធាន ១២*ស្ទួនពីរ*(៤) នៃវិធានផ្ទៃក្នុងចែងថា "សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរួមមាន មេធាវីជាតិ និងមេធាវីអន្តរជាតិដែលត្រូវបានជ្រើសរើស និង ផ្តល់មូលនិធិដោយ អង្គជំនុំជម្រះវិសាមញ្ញ និងត្រូវបានគាំពារដោយបុគ្គលិកមួយចំនួនទៀតតាមការចាំបាច់។ មុខងាររបស់ពួកគាត់ត្រូវចាប់ផ្តើម នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ..."។ វិធាន ១២*ស្ទួនពីរ* (៥) នៃវិធានផ្ទៃក្នុងចែងថា មុខងារសំខាន់ៗរបស់សហមេធាវីនាំមុខរួមមាន "ការតំណាងឲ្យផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ ដូចដែលបានចែងនៅក្នុងវិធាន ២៣ (១) និង (២) នៃវិធានផ្ទៃក្នុង" និងមាន "ការទទួលខុសត្រូវជាចុងក្រោយទៅកាន់តុលាការ សំរាប់ការផ្តល់ការអះអាង និង យុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការអំពីផលប្រយោជន៍ របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយនោះ ចាប់ពី ដំណាក់កាលជំនុំជម្រះឡើងទៅ"។

14. វិធាន ២៣(១) នៃវិធានផ្ទៃក្នុងចែងថា "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖ ក-ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់"។

15. វិធាន ២៣(៣) ចែងថា "ដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមជាលក្ខណៈបុគ្គល នៅក្នុងដំណាក់កាលមុនជំនុំជម្រះ។ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវរួមបញ្ចូលក្រុមតែមួយដែលផលប្រយោជន៍របស់ពួកគាត់ ត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងវិធាន ១២ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវជំនួយដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដូចមានចែងនៅក្នុងវិធាន ១២ *ស្ទួនពីរ* (៣) នៃវិធានផ្ទៃក្នុង..."។

16. វិធាន ២៣*ស្ទួនពីរ*(១) នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ចាប់ពីពេលចេញដីកាដំណោះស្រាយតទៅ ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយត្រូវតំណាងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប នៅគ្រប់ពេលទាំងអស់។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសមស្របនានាសម្រាប់គោលបំណងនេះតាមពេលវេលាសមរម្យដែលអាចអនុវត្តបាន ប៉ុន្តែយ៉ាងយូរបំផុត នៅពេលចេញដីកាដំណោះស្រាយ។

17. ពាក់ព័ន្ធនឹងការពិនិត្យមើលសំណុំរឿង វិធាន ៦៩(៣) នៃវិធានផ្ទៃក្នុងចែងថា "ការដាក់ពាក្យប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ"។

18. ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខទៅ អ.ជ.ត.ក វិញ វិធាន ១០៦(១) នៃវិធានផ្ទៃក្នុងចែងថា "បើមានការដាក់ពាក្យសុំប្ដឹងសាទុក្ខ ឬពាក្យសុំប្ដឹងសាទុក្ខភ្លាមៗ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវជូនដំណឹងជាបន្ទាន់ដល់គ្រប់ភាគី និងមេធាវីទាំងអស់របស់ពួកគេ"។ ចំណែកឯវិធាន ១០៦(៣) នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកដែលពាក់ព័ន្ធថា "ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែតំណាងដោយសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី"។

19. ដើមបណ្តឹងរដ្ឋប្បវេណីជាភាគីនៃកិច្ចដំណើរការនីតិវិធី[14]។ វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុងចែងថា "លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន"។

20. អ.ជ.ត.ក បានសម្រេចថា សិទ្ធិនានាដែលមានចែងក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវយកមកអនុវត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណី[15]។ មាត្រា ១៤(១) ចែងថា "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន"[16]។

## IV. សារណា

21. នាពេលបច្ចុប្បន្ន ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ពុំមានការតំណាងតាមផ្លូវច្បាប់ច្បាស់លាស់ នៅចំពោះមុខ អ.ជ.ត.ក ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ខ្លួន នៅក្នុងបណ្តឹងសាទុក្ខដែលកំពុងរង់ចាំសេចក្តីសម្រេចនេះទេ។

22. ខ្លឹមសារនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗរបស់ ស.ព.អ នៅចំពោះមុខ អ.ជ.ត.ក បង្ហាញការពិតឥតសង្ស័យថា នៅក្នុងឯកសារនោះ ស.ព.អ មានចេតនា និងបំណងក្នុងការដាក់បណ្តឹងសាទុក្ខភ្លាមៗ។ ការណ៍ដែល ស.ព.អ បានផ្ញើបណ្តឹងសាទុក្ខនោះតាមរយៈអ៊ីមែលទៅកាន់ភាគីមួយចំនួននៅថ្ងៃទី០៤

---

[14] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) សទ្ទានុក្រម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (កំណត់និយមន័យពាក្យ "ភាគី" ដោយរាប់បញ្ចូលទាំងសហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី។

[15] សំណុំរឿង ០០២ ឯកសារ F26/2/2 សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥, កថាខណ្ឌ ៧ (ដោយទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី "ទទួលបានសិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានចែងក្នុងមាត្រា ១៤(១) នៃ ICCPR" និង "មានតួនាទីជាក់លាក់ និងមានកម្រិតនៅក្នុងកិច្ចដំណើរការនីតិវិធី ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក")។

[16] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, 999 U.N.T.S. 171 មាត្រា១៤(១)។

ខែឧសភា ឆ្នាំ២០២០ ក៏បង្ហាញច្បាស់ពីចំណុចនេះផងដែរ[17]។ ទោះបីមេធាវីការពារក្តីបានធ្វើការឆ្លើយតបជាទម្រង់លិខិតក៏ដោយ តែប្រការនេះមិនអាចកែប្រែអង្គហេតុដែលថា បញ្ហានានានៅចំពោះមុខអង្គជំនុំជម្រះត្រូវយកមកសម្រេចតាមផ្លូវតុលាការដែរ គឺថា៖ យ៉ាងហោចណាស់ អង្គជំនុំជម្រះត្រូវសម្រេចទៅលើបញ្ហានៃ*ភាពអាចទទួលយកបាន*នៃបណ្តឹងសាទុក្ខភ្លាមៗរបស់ ស.ព.អ។ ទោះបីមានការអះអាងថា អង្គជំនុំជម្រះ "មិនបានទទួលយកតាមផ្លូវច្បាប់" ក៏ដោយ ក៏មេធាវីការពារក្តីបានដាក់ទឡ្ហីករណ៍របស់ខ្លួនដែរពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ នៅចំពោះមុខចៅក្រម[18]។ យ៉ាងហោចណាស់អង្គជំនុំជម្រះបានទទួលយកទៅពិនិត្យយ៉ាងច្បាស់ដែរ នូវបញ្ហានៃភាពអាចទទួលយកបាន។

23. ទោះជាយ៉ាងណាក្តី មកទល់នឹងពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីពុំមានឱកាសពិតប្រាកដក្នុងការចូលរួមសវនាការទៅលើបញ្ហានេះទេ ដោយសារពុំមានភាពប្រាកដប្រជាពាក់ព័ន្ធនឹងការតំណាងផ្លូវច្បាប់របស់ខ្លួន។ អនុលោមតាមវិធានផ្ទៃក្នុង មេធាវីតំណាងពុំមានសិទ្ធិមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលទេ។ តុលាការមិនបានទទួលស្គាល់អាណត្តិការងាររបស់សហមេធាវីនាំមុខនៅក្នុងសំណុំរឿង ០០៤/២ ទេ ហើយសហមេធាវីនាំមុខមិនត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿងទេ[19]។ ផលវិបាកនៃកាលៈទេសៈទាំងនេះគឺថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមានតំណាងផ្លូវ

---

[17] *សូមមើល* អ៊ីមែលពី Brenda Hollis សហព្រះរាជអាជ្ញាអន្តរជាតិ កម្មវត្ថុ៖ សំណើសុំសំណៅថតចម្លងនៃបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ដាក់ជូន អ.ជ.ត.ក ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយ អ.ជ.ស.ដ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ [មូលដ្ឋានសំអាងផ្លូវច្បាប់ទី ១]។ ក្នុងនោះ អ៊ីមែលនេះបានលើកឡើងថា៖ "បណ្តឹងសាទុក្ខជាបន្ទាន់នេះត្រូវបានដាក់ជាឯកសារក្រដាស ដោយសារតែការដាក់ឯកសារតាមប្រព័ន្ធអេឡិកត្រូនិច នៃប្រព័ន្ធគ្រប់គ្រងតុលាការ ពុំទាន់បានផ្តល់ ឲ្យសម្រាប់ការដាក់ឯកសារជូនអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងករណីនេះនៅឡើយទេ"។

[18] សំណុំរឿង ០០៤/២ ឯកសារ **E004/2/1/1** ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០, ទំព័រ ២-៦។

[19] *សូមមើល* អ៊ីមែលពីលោកស្រី Megan Hirst សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ កម្មវត្ថុ: សំណើសុំសំណៅថតចម្លងនៃបណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ ដោយ អ.ជ.ស.ដ, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ [មូលដ្ឋានសំអាងផ្លូវច្បាប់ទី ២]។ ជាការគួរឲ្យកត់សម្គាល់ ចំពោះសហព្រះរាជអាជ្ញាជាតិ និង អន្តរជាតិ ពុំមានការបញ្ជាក់នៅក្នុងក្រមខណ្ឌច្បាប់របស់ អ.វ.ត.ក ថា អាណត្តិរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានកំណត់ចំពោះរឿងក្តីជាក់លាក់នោះទេ។

ច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលពួកគេពិតមានសិទ្ធិក្នុងការបញ្ចេញទស្សនៈយោបល់ និងសិទ្ធិទទួលបានផលប្រយោជន៍ចំពោះលទ្ធផលនានា។

24. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា៖

(ក) ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការចូលរួមសវនាការនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ នៅចំពោះមុខ អ.ជ.ត.ក។

(ខ) សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ សំដៅដល់សិទ្ធិមានតំណាងផ្លូវច្បាប់ រួមទាំង ភាពប្រាកដប្រជាពាក់ព័ន្ធនឹងការតំណាងផ្លូវច្បាប់របស់ខ្លួន។

(គ) អនុលោមតាមវិធានផ្ទៃក្នុង សហមេធាវីនាំមុខគឺជាតំណាងដ៏ត្រឹមត្រូវរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់សេចក្តីសន្និដ្ឋានជូនចំពោះ អ.ជ.ត.ក និង គួរត្រូវបានទទួលស្គាល់នូវភាពជាតំណាងនេះដោយអង្គជំនុំជម្រះ។

(ឃ) អនុលោមតាមវិធានផ្ទៃក្នុង សហមេធាវីនាំមុខគួរទទួលបានការអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង ០០៤/២។

(ង) ជាជម្រើសម្យ៉ាងទៀត ប្រសិនបើសហមេធាវីនាំមុខមិនត្រូវបានទទួលស្គាល់ និងទទួលការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ០០៤/២ ឱ្យបានទាន់ពេលវេលាទេ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានការទទួលស្គាល់ថាមានតួនាទីក្នុងការដាក់សេចក្តីសន្និដ្ឋាននៅចំពោះមុខ អ.ជ.ត.ក។

(ច) ដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីចូលរួមសវនាការ បន្ទាប់ពីមានដំណោះស្រាយចំពោះបញ្ហានេះ។

## ក. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការចូលរួមសវនាការ នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

25. ដើមបណ្តឹងរដ្ឋប្បវេណីជាភាគីមានសិទ្ធិនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ហើយជាពិសេសទទួលបានសិទ្ធិនានាដែលមានចែងនៅក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ នៅក្នុងសំណុំរឿង ០០១ចៅក្រម Lavergne បានទទួលស្គាល់ថា "លើកលែង

តែវិធានផ្ទៃក្នុងមិនបានចែងអំពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬបានរិតត្បិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្បាស់នោះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដូចគ្នាទៅនឹងភាគីដទៃទៀតនៃរឿងក្តី"[20]។ គាត់ក៏បានកត់សម្គាល់ផងដែរថា សិទ្ធិផ្នែកនីតិវិធីទាំងនេះជាច្រើនកើតចេញពីគោលការណ៍ចំពោះមុខដែលបានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[21] ដែលជាចំណុចសំខាន់នៃសិទ្ធិនេះគឺឱកាសសម្រាប់ភាគីទាំងអស់*ក្នុងការ*ចូលរួមសវនាការ ទៅលើបញ្ហាណាមួយ មុនពេលចេញសម្រេចទៅលើបញ្ហានោះ[22]។ វិធាន ២១ នៃវិធានផ្ទៃក្នុងក៏តម្រូវផងដែរថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវការពារសិទ្ធិរបស់ជនរងគ្រោះ និងរក្សាតុល្យភាពនៃសិទ្ធិនានារវាងភាគី។

26. វិធាន ១០៦(៣) នៃវិធានផ្ទៃក្នុងចែងច្បាស់ឱ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីទាំងនៅក្នុងបណ្តឹងសាទុក្ខទៅលើសាលក្រម និងបណ្តឹងសាទុក្ខភ្លាមៗ។ ការពិត អ.ជ.ត.ក ធ្លាប់បានសម្រេចជាពិសេសថា ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងសាទុក្ខចំពោះសាលក្រមដែលដាក់ដោយមេធាវីការពារក្តី នៅពេលមូលដ្ឋាននៃបណ្តឹងសាទុក្ខមានឥទ្ធិពលដោយផ្ទាល់ទៅលើសិទ្ធិនិងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី[23]។ ស្រដៀងគ្នាដែរ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យចូលរួមសវនាការ ជាការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ ក.ស.ព

---

[20] សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក ("សំណុំរឿង ០០១") ឯកសារ E72/3 សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ យោបល់ខ្វែងរបស់ចៅក្រម Lavergne, កថាខណ្ឌ ១៣។ *សូមមើល ផងដែរ* សំណុំរឿង ០០២ ឯកសារ F10/2 សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទ២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១២-១៤។

[21] *ដូចខាងលើ*, កថាខណ្ឌ ១៧។

[22] សំណុំរឿង ០០២, ឯកសារ E163/5/1/13, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៤៤, ៥០, ជើងទំព័រយោងលេខ ១១០។

[23] សំណុំរឿង ០០២ ឯកសារ F10/2 សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤។ សំណុំរឿង ០០២ ឯកសារ F52/1 សេចក្តីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតប របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២០។ *សូមមើល ផងដែរ* សំណុំរឿង ០០១ ឯកសារ F28 សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, កថាខណ្ឌ ៤៨៨។

រួមទាំងទៅលើបញ្ហានៃភាពអាចទទួលយកបាន[24]។ ហេតុនេះ មានការបង្កើតយ៉ាងត្រឹមត្រូវនៅចំពោះមុខតុលាការគឺថា តាមរយៈសិទ្ធិ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមសវនាការទៅលើបណ្តឹងសាទុក្ខដែលមានឥទ្ធិពលទៅលើសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួន។

27. បណ្តឹងសាទុក្ខភ្លាមៗរបស់ ស.ព.អ ពាក់ព័ន្ធនឹងសំអាងហេតុដែលសំណុំរឿង ០០៤/២ គួរបញ្ជូនទៅជំនុំជម្រះ។ នេះជាបញ្ហាដែលប៉ះពាល់ជាសារវ័ន្តទៅលើផលប្រយោជន៍ និងសិទ្ធិនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះនេះបានទទួលស្គាល់នូវទិដ្ឋភាពផ្តល់សំណងនៃការងាររបស់តុលាការនេះថា៖

> ទោះបីជាសំណងផ្លូវចិត្ត និងសមូហភាពមិនអាចផ្តល់សំណងពេញលេញដល់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សខាងរូបកាយ ឬខាងសេដ្ឋកិច្ចក្តី ក៏គោលបំណងនៃសំណងទូទៅផ្សេងទៀតត្រូវបានបំពេញនៅចំពោះមុខ អ.វ.ត.ក ក្នុងកម្រិតដែលអាចឆ្លើយតបទៅនឹង "ការរំលោភបំពានខាងចិត្តសាស្ត្រ ផ្លូវចិត្ត និងនិមិត្តរូប"។ *ករណីនេះអាចសម្រេចបានតាមរយៈ៖ "ការផ្ទៀងផ្ទាត់ អង្គហេតុ និងការបង្ហាញការពិតពេញលេញ និងជាសាធារណៈ" ដូចដែលលើកឡើងដោយសំអាងហេតុរបស់អង្គជំនុំជម្រះនានា តាមរយៈការចូលរួមរបស់ជនរងគ្រោះ ក្នុងកិច្ចដំណើរការនីតិវិធី* និងការទទួលស្គាល់ជាបុគ្គលនៅក្នុងសាលក្រម និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលបង្ហាញនូវការទទួលស្គាល់ជាសាធារណៈនូវការឈឺចាប់របស់ពួកគាត់[25]។

28. ប្រសិនបើសំណុំរឿង ០០៤/២ មិនបន្តដំណើរទៅមុខទេ លទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវទម្រង់នៃសំណងទាំងនេះនឹងត្រូវបាត់បង់។ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការទៅលើបញ្ហានានា ដែលមានឥទ្ធិពលទៅលើសិទ្ធិនៃការចូលរួមរបស់ពួកគេត្រូវ

---

[24] *សូមមើល ឧទា.* សំណុំរឿង ០០២ ឯកសារ E163/5/1/13, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១៣។

[25] សំណុំរឿង ០០១ ឯកសារ F28 សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦៦១ (មានសេចក្តីបញ្ជាក់បន្ថែម)។

របញ្ចូលនូវ សិទ្ធិក្នុងការចូលរួមសវនាការទៅលើបញ្ហានានាដែល*រំលត់*សិទ្ធិនៃការចូលរួមទាំងនេះ[26]។

**ខ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ សំដៅលើសិទ្ធិមានតំណាងផ្លូវច្បាប់ រួមទាំង ភាពប្រាកដប្រជា ពាក់ព័ន្ធនឹងការតំណាងផ្លូវច្បាប់របស់ខ្លួន**

29. ដើម្បីឱ្យសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការនៅចំពោះមុខ អ.ជ.ត.ក មានប្រសិទ្ធភាព ជាការចាំបាច់ដែលពួកគេត្រូវមានតំណាងតាមច្បាប់។

30. វិធាន ២៣*ស្ទួនពីរ* (១) នៃវិធានផ្ទៃក្នុង កំណត់ជាកាតព្វកិច្ចនូវការតំណាងផ្លូវច្បាប់ ក្រោយពេលចេញដីកាដំណោះស្រាយ។ ដូចគ្នាដែរ វិធាន ២៣*ស្ទួនពីរ*(២) នៃវិធានផ្ទៃក្នុង ចែងច្បាស់ថា ចាប់ពីដំណាក់កាលនេះតទៅ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចតំណាងដោយខ្លួនឯងបានទេ៖ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តតាមរយៈមេធាវីរបស់ខ្លួន។ ហេតុនេះ សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងតាមរយៈមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬសហមេធាវីនាំមុខជានិច្ច[27]។

31. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងដោយមេធាវី គឺស្ថិតក្នុងចំណោមសិទ្ធិនានាផ្នែកនីតិវិធីដែលផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេ

---

[26] *សូមមើល ឧទា.* សំណុំរឿង ០០២ ឯកសារ **E163/5/1/13**, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១៣, កថាខណ្ឌ ៤៤, ៥០, ជើងទំព័រយោងលេខ ១១០។

[27] សូម្បីតែមុនពេលដែលវិធាន ២៣*ស្ទួនបី* ត្រូវបានបន្ថែមទៅក្នុងវិធានផ្ទៃក្នុង នៅក្នុងឆ្នាំ ២០១០ ក៏ដោយ ក៏សេចក្តីសម្រេចមួយចំនួនដោយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ បានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចដាក់សារណានានា ក្រៅពីតាមរយៈមេធាវីបានឡើយ។ *សូមមើល* សំណុំរឿង ០០២ ឯកសារ **C22/I/46** សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ខំ ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៨។ សំណុំរឿង ០០២ ឯកសារ **C22/I/54** សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានសម្រេចផ្ទាល់មាត់ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ អំពីសំណើសុំលើកអំណះអំណាងនៅចំពោះមុខតុលាការដោយផ្ទាល់ របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨។ សំណុំរឿង ០០២ ឯកសារ **C22/I/68** សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨។ សំណុំរឿង ០០២ ឯកសារ **C22/I/69**, សេចក្តីបង្គាប់ស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨។

ណី[28]។ ទោះជាយ៉ាងណាក្តី អ.វ.ត.ក បានបង្កើតប្រព័ន្ធស្មុគ្រស្មាញមួយសម្រាប់ការធ្វើជាតំណាងផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុនេះ ទោះបីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានតំណាងដោយមេធាវីម្នាក់ ឬច្រើននាក់ ក្នុងគោលបំណងបំពេញទៅតាមកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ក្តី តែមេធាវីទាំងនេះពុំមានតួនាទីនៅគ្រប់ផ្នែកនៃតុលាការនេះ ឬនៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់នោះទេ។ ឧទាហរណ៍ នៅដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ វចនាសម្ព័ន្ធសំខាន់ដែលយកមកប្រើប្រាស់គឺ សហមេធាវីនាំមុខមានអំណាចផ្តាច់មុខក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរ ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី។

32. ដើម្បីឱ្យប្រព័ន្ធនេះសម្រេចបាននូវការតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងមានអត្ថន័យ ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិក្នុងការចូលរួមសវនាការបាន ជាការសំខាន់គឺមានភាពប្រាកដប្រជាពាក់ព័ន្ធនឹងមេធាវីដែលទទួលបានសិទ្ធិអំណាចក្នុងការតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ។ នាពេលបច្ចុប្បន្ន ភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងការតំណាងដើមបណ្តឹងរដ្ឋប្បវេណីរារាំងមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមយ៉ាងមានប្រសិទ្ធភាព និងមានអត្ថន័យទៅក្នុងកិច្ចដំណើរការនីតិវិធីនានា ធ្វើឱ្យបាត់បង់នូវសិទ្ធិរបស់ពួកគេក្នុងការចូលរួមសវនាការ និងបង្អាក់នូវតុល្យភាពរវាងសិទ្ធិនានាក្នុងចំណោមភាគី *ទាំងអស់*។ ហេតុនេះ ជាការសំខាន់គឺត្រូវផ្តល់នូវការណែនាំច្បាស់លាស់ ពាក់ព័ន្ធនឹងតំណាងផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.ជ.ត.ក។ ក្នុងនាមជាជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មស្ថិតក្នុងវិសាលភាពនៃដីកាដំណោះស្រាយ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិច្បាស់លាស់ និងដោយផ្ទាល់ក្នុងការចូលរួមសវនាការ ទាំងទៅលើភាពអាចទទួលយកបាន និងអង្គសេចក្តីនៃបណ្តឹងសាទុក្ខផ្សេងៗរបស់ ស.ព.អ។ បញ្ហាថាតើ*នរណា*អះអាងអំពីសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន មិនអាចជាការរារាំងដល់ការប្រើប្រាស់សិទ្ធិនេះបានទេ។ ហេតុនេះ បញ្ហានេះត្រូវយកមកដោះស្រាយជាបន្ទាន់[29]។ សេចក្តីសន្និដ្ឋាននានារបស់មេធាវី

---

[28] សំណុំរឿង ០០១ ឯកសារ F28 សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៤៨៨-៨៩។

[29] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលើកឡើងដោយគោរពថា ការពុំមានសាលដីកាឱ្យទាន់ពេលវេលាពី អ.ជ.ត.ក សម្រេចលើបណ្តឹងសាទុក្ខដែលបានលើកឡើង នោះវានឹងរំលោភទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចគ្នា ដោយសារតែវាមានឥទ្ធិពលក្នុងការបញ្ជាក់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ដូចបានលើកឡើងលម្អិតនៅក្នុងសារណា ដែលបានស្នើសុំដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ គឺរំលោភទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទទួលបានសច្ចភាព និងតម្លាភាពតាមផ្លូវច្បាប់ ព្រមទាំងសិទ្ធិទទួលបានយុត្តិធម៌។ *សូមមើល* ឧបសម្ព័ន្ធ ក។

តំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដំណោះស្រាយប្រសើរចំពោះបញ្ហានេះ នឹងលើកឡើងដូចខាងក្រោម។

**គ. អនុលោមតាមវិធានផ្ទៃក្នុង សហមេធាវីនាំមុខគួរត្រូវបានទទួលស្គាល់ថាជាតំណាងដ៏ត្រឹមត្រូវ ក្នុងការដាក់ឯកសារនានានៅចំពោះមុខ អ.ជ.ត.ក និង ទទួលការអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿង ០០៤/២**

33. ទោះបីវិធានផ្ទៃក្នុងនៅ អ.វ.ត.ក ទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះក៏ដោយ តែរចនាសម្ព័ន្ធពីរដាច់ពីគ្នានៅ អ.វ.ត.ក បានបង្កឲ្យមានគម្លាតមិនត្រឹមត្រូវនៅក្នុងការតំណាងជនរងគ្រោះនៅ អ.ជ.ត.ក ទៅលើបញ្ហានានាដែលត្រូវបានប្តឹងសាទុក្ខនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ។ កិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះដំណើរការនៅចំពោះមុខ ក.ស.ច.ស ដែលប្តឹងឧទ្ធរណ៍ទៅ អ.ប.ជ[30]។ បន្ទាប់មក កិច្ចដំណើរការជំនុំជម្រះដំណើរការនៅចំពោះមុខ អ.ជ.ស.ដ ដែលប្តឹងសាទុក្ខទៅ អ.ជ.ត.ក[31]។ វិសោធនកម្មដែលបានធ្វើពាក់ព័ន្ធនឹងការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ ឆ្នាំ២០០៨ បានណែនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំការតំណាងជាលក្ខណៈបុគ្គល ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលមុនការជំនុំជម្រះ (ហេតុនេះ នៅចំពោះមុខ ក.ស.ច.ស ឬ អ.ប.ជ)[32] ហើយនៅពេលកិច្ចដំណើរការនីតិវិធីចូលទៅដល់ អ.ជ.ស.ដ (ឬបណ្តឹងសាទុក្ខពីអង្គជំនុំជម្រះនេះទៅ អ.ជ.ត.ក) សហមេធាវីនាំមុខជាអ្នកដាក់សេចក្តីសន្និដ្ឋាន[33]។ ទោះជាយ៉ាងណាក្តី វិសោធនកម្មទាំងនេះទៅលើវិធានផ្ទៃក្នុង មិនបានរំពឹងគិតទៅដល់កាលៈទេសៈនៃកិច្ចដំណើរការនីតិវិធីនាពេល

---

[30] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) វិធាន ៧៣, វិធាន ៧៤, ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។ *សូមមើល ផងដែរ ដូចខាងលើ*។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩), វិធាន ២៣*ស្ទួន*(២) និង(៣), វិធាន ២៩(៨), ៣១(១០), ៥៨(៦), ៦៣(៤), ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[31] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩), វិធាន ១០៤, វិធាន ១០៥, ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។ *សូមមើល ផងដែរ* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩), វិធាន ២៩(៨) វិធាន ៨២(៦) ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[32] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩), វិធាន ២៣(៣), ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[33] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) វិធាន ១២*ស្ទួនពីរ*(៤) វិធាន ២៣(៣) ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

បច្ចុប្បន្ននេះ គឺថា បញ្ហាត្រូវបានបញ្ជូនទៅ អ.ជ.ត.ក ទោះបីចំណុចខ្លះកំពុងដំណើរការនៅក្នុងដំណាក់កាលមុនការជំនុំជម្រះក៏ដោយ។

34. បើតាមរូបភាពខាងក្រៅ វិធាន ១០៦(៣) នៃវិធានផ្ទៃក្នុងហាក់ដូចជាចែងច្បាស់គឺថា៖ នៅពេលមានបណ្តឹងសាទុក្ខភ្លាមៗត្រូវបានដាក់ និងជូនដំណឹងទៅតាមវិធាន ១០៦(១) "ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែតំណាងដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី"។ ពុំមានការកម្រិតណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលថា ចំណុចនេះជាករណីតែមួយគត់ដែល អ.ជ.ស.ជ ត្រូវបានទទួលស្គាល់ជាផ្លូវការរួចហើយថាបានទទួលយកសំណុំរឿង នោះទេ។ ប្រព័ន្ធដែលបង្កើតឡើងវិធានផ្ទៃក្នុងកំណត់ច្បាស់ថា នៅពេលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបំពេញតួនាទីដោយផ្ទាល់នៅចំពោះមុខ ក.ស.ច.ស និង អ.ប.ជ សហមេធាវីនាំមុខបំពេញតួនាទីនៅចំពោះមុខ អ.ជ.ស.ជ និង អ.ជ.ត.ក។ មានការចែងយ៉ាងច្បាស់រួចមកហើយថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចដាក់ឯកសារជាធម្មតានៅចំពោះ អ.ជ.ស.ជ បានទេ[34]។

35. ការពិតគឺថា វិធាន ២៣(៣) នៃវិធានផ្ទៃក្នុងចែងថា តួនាទីជាតំណាងរបស់សហមេធាវីនាំមុខ ចាប់ផ្តើមនៅដំណាក់កាលជំនុំជម្រះ[35]។ ទោះជាយ៉ាងណាក្តី វិធានផ្ទៃក្នុងចែងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមជាលក្ខណៈបុគ្គលបានតែនៅដំណាក់កាលមុនការជំនុំជម្រះប៉ុណ្ណោះ[36]។ ហេតុនេះ វិធាននេះមិនអាចដោះស្រាយបញ្ហាថា*នរណា*ធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះទេ ក្នុងខណៈដែលដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ទោះបីមុនការជំនុំជម្រះ ឬក្នុងពេលជំនុំជម្រះ គឺជាបញ្ហាវិវាទតែម្តង។

36. អនុលោមតាមសំអាងហេតុទាំងនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីនាពេលនេះស្ថិតនៅក្នុងការទទួលខុសត្រូវរបស់សហមេធាវីនាំមុខ។ ទោះជាយ៉ាង

---

[34] សំណុំរឿង ០០២ ឯកសារ E74 ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ទំព័រ ៣។

[35] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩), វិធាន ១២*ស្ទួនពីរ*(៤) វិធាន ២៣(៣) ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[36] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) វិធាន ២៣(៣) ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥។

ណាក្តី ការលំបាកបានកើតឡើងដោយសារតុលាការនៅតែបន្តបដិសេធមិនទទួលស្គាល់ និងមិនផ្តល់ការអនុញ្ញាតដល់សហមេធាវីនាំមុខក្នុងការចូលពិនិត្យមើលសំណុំរឿង។ នេះជារឿងគួរឱ្យភ្ញាក់ផ្អើលជាពិសេស ដោយសារ ទោះបីមានការយល់ឃើញថា សហមេធាវីនាំមុខពុំមានតួនាទីក្នុងការធ្វើសេចក្តីសន្និដ្ឋានក្តី តែវិធាន ៦៩(៣) នៃវិធានផ្ទៃក្នុងតម្រូវយ៉ាងច្បាស់ថា ពួកគេអាចចូលពិនិត្យមើលសំណុំរឿងបានតាំងពីមុនពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះម៉្លេះ ដើម្បីពួកគេអាចត្រៀមខ្លួនជាមុនក្នុងករណីមានការជំនុំជម្រះ។

37. ដូចដែលធ្លាប់បានលើកឡើងពីមុននៅចំពោះមុខ អ.ប.ជ[37] ការមិនទទួលស្គាល់សហមេធាវីនាំមុខឱ្យបានទាន់ពេលវេលាធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ជនរងគ្រោះ ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីយ៉ាងមានអត្ថន័យ និងប្រកបដោយប្រសិទ្ធភាព។ វិធាន ៦៩(៣) នៃវិធានផ្ទៃក្នុងប្រមើលមើលយ៉ាងត្រឹមត្រូវពីភាពចាំបាច់ដើម្បីឱ្យសហមេធាវីមានភាពស៊ាំទៅនឹងសំណុំរឿង ចាប់ពីពេលចេញដីកាដំណោះស្រាយ ដើម្បីធានាថា ពួកគេបានត្រៀមខ្លួនយ៉ាងពេញលេញក្នុងការតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងមានប្រសិទ្ធភាព នៅពេលបណ្តឹងឧទ្ធរណ៍/សាទុក្ខមុនការជំនុំជម្រះបញ្ចប់។ ជារឿងមិនសមហេតុផលទេ ដែលមេធាវីអាចបំពេញតួនាទីទៅតាមកាលកំណត់នានាដែលមានចែងក្នុងវិធាន ៨០ និង ៨៩ នៃវិធានផ្ទៃក្នុង ចំពោះការដាក់សេចក្តីសន្និដ្ឋានលើកដំបូងនៅដំណាក់កាលជំនុំជម្រះ នៅពេលពួកគេមានពេលវេលាមិនដល់មួយខែផង ក្នុងការអានឯកសារភស្តុតាង និងសេចក្តីសន្និដ្ឋានពីមុនៗរាប់ពាន់ទំព័រ និង ត្រូវផ្សាំខ្លួនទៅនឹងស្ថានភាព និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរាប់រយ ឬរាប់ពាន់នាក់នោះ។ នៅក្នុងករណីនាពេលនេះ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងយ៉ាងមានប្រសិទ្ធភាពនៅចំពោះមុខ អ.ជ.ស.ដ និង អ.ជ.ត.ក ដោយសហមេធាវីនាំមុខដែលបានស្វែងយល់សំណុំរឿងនេះយ៉ាងត្រឹមត្រូវ ត្រូវបានរំលោភបំពាន។

## ឃ. ប្រយោជន៍យុត្តិធម៌តម្រូវឱ្យអនុញ្ញាតឱ្យមានតំណាងផ្លូវច្បាប់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួននៅចំពោះមុខ អ.ជ.ត.ក

38. បរិយាកាសទូទៅនៃភាពមិនប្រក្រតីផ្នែកនីតិវិធី ការប្រាស្រ័យទាក់ទងដែលមិនអាចទុកចិត្តបាន និងការភាន់ច្រឡំដែលបានពិពណ៌នានៅក្នុងសេចក្តីសន្និដ្ឋាននេះ និងសេចក្តីសន្និដ្ឋានផ្សេងទៀតរបស់

[37] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យ អ.ប.ជ ផ្តល់ការធានា កថាខណ្ឌ ៣៩-៤០។

ដើមបណ្ដឹងរដ្ឋប្បវេណី[38] នៅតែបន្តគ្របដណ្ដប់នៅក្នុងសំណុំរឿង ០០៤/២ និងនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.ជ.ត.ក នាពេលនេះទៀត។ ហេតុនេះ ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ និងការទទួលបានការចូលរួមដោយស្មើភាព និងដោយយុត្តិធម៌ ក្នុងនាមជាភាគីនៃកិច្ចដំណើរការនីតិវិធីទទួលរងព្យសនកម្មយ៉ាងធ្ងន់ធ្ងរ រួមទាំងសមត្ថភាពរបស់ពួកគេក្នុងការទទួលការជូនដំណឹង និងឆ្លើយតបទៅនឹងសារណានានាដែលដាក់ដោយភាគីផ្សេងទៀត និងអង្គជំនុំជម្រះនៃតុលាការ។ ជាប្រយោជន៍យុត្តិធម៌គឺថា ទោះបី អ.ជ.ត.ក យល់ឃើញពីកាលបរិច្ឆេទចុងក្រោយដែលសមរម្យ សម្រាប់ដាក់សេចក្ដីសន្និដ្ឋានដែលបានស្នើសុំរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឬសហមេធាវីនាំមុខបែបណាក្ដី[39] ក៏នៅក្នុងការពិចារណាទៅលើកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះគួរសំអាងទៅលើយុត្តាធិការពីធម្មជាតិរបស់ខ្លួន និង/ឬ វិធាន ៩៣ នៃវិធានផ្ទៃក្នុង ដើម្បីអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ និងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមសវនាការបាន[40] ។

## ង. ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីដាក់សេចក្ដីសន្និដ្ឋានទៅលើបញ្ហានានានៅចំពោះមុខ អ.ជ.ត.ក បន្ទាប់ពីមានការសម្រេចទៅលើការតំណាងផ្លូវច្បាប់របស់ខ្លួន

39. ដោយសារពុំមានភាពប្រាកដប្រជាចំពោះតួនាទីរបស់ខ្លួន ក្នុងការដាក់សេចក្ដីសន្និដ្ឋាននៅចំពោះមុខ អ.ជ.ត.ក ប្រសិនបើអង្គជំនុំជម្រះសម្រេចថា សហមេធាវីនាំមុខមានតួនាទីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនោះ សហមេធាវីនាំមុខត្រូវការពេលវេលាបន្ថែមក្នុងការសេចក្ដីសន្និដ្ឋានរបស់ខ្លួនទៅលើបញ្ហានានានៃបណ្ដឹងសាទុក្ខ ដោយផ្ដល់រយៈពេល ១០ ថ្ងៃដល់ពួកគេ ចាប់ពី អ.ជ.ត.ក ចេញសេចក្ដីសម្រេចលើសេចក្ដីសន្និដ្ឋាននេះ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ថា ការផ្ដល់ពេលវេលានេះនឹងមិនប៉ះពាល់ដល់ភាគីផ្សេងទៀត ឬបង្កឲ្យមានការពន្យារពេលឥតប្រយោជន៍នោះទេ ដោយសារវាជាការធានានូវតុល្យភាព និងគោរពដល់សិទ្ធិនិងផល

[38] *សូមមើល ឧទា.*, សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យ អ.ប.ជ ផ្ដល់ការធានា។

[39] *សូមមើល* ឧបសម្ព័ន្ធ ១។

[40] *សូមមើល* សំណុំរឿង ០០៤/១, ឯកសារ **D308/3/1/8**, សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឲ្យដាក់សារណា, ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧, ទំព័រ ៦-៧ (អង្គបុរេជំនុំជម្រះសំអាងលើយុត្តាធិការ ដែលមានមកជាមួយស្រាប់ និសំអាងងលើវិធាន ៣៣ ដើម្បីអនុញ្ញាដើមបណ្ដឹងរដ្ឋប្បវេណីដាក់សារណាស្ដីពីបញ្ហាជាក់លាក់ ដែលប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះអំពីការប្ដឹងឧទ្ធរណ៍)។

ប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ហើយវាគ្រាន់តែបន្ថែមពេលវេលាបន្តិចបន្តួចទៅក្នុងកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ។

## V. សំណើ

40. ទាក់ទិននឹងការណ៍ដែលតុលាការនៅតែបន្តមិនការពារ និងធានានូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ការណ៍ដែលថា កិច្ចដំណើរការនីតិវិធីបានទៅដល់ អ.ជ.ត.ក ទៅហើយ និងផលប្រយោជន៍រួមរបស់ភាគីទាំងអស់ ក្នុងការបញ្ចៀសនូវការពន្យារពេលបន្ថែមទៀតនោះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

ក. **ទទួលស្គាល់** សហមេធាវីនាំមុខជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងសមរម្យក្នុងការដាក់សេចក្តីសន្និដ្ឋាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

ខ. **បង្គាប់**ឲ្យការិយាល័យរដ្ឋបាលអនុញ្ញាតឲ្យសហមេធាវីនាំមុខចូលពិនិត្យមើលសំណុំរឿង ០០៤/២ និង

គ. **ផ្តល់**ការពន្យារពេលសមរម្យដល់សហមេធាវីនាំមុខ ក្នុងការដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនក្នុងរយៈពេល ១០ថ្ងៃ ចាប់ពីពេល អ.ជ.ត.ក ចេញសេចក្តីសម្រេចលើសំណើនេះ។

ឃ. ឬ ជាជម្រើសម្យ៉ាងទៀត **ទទួលស្គាល់** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថាមានតួនាទីក្នុងការដាក់សេចក្តីសន្និដ្ឋាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើសហមេធាវីនាំមុខមិនត្រូវបានទទួលស្គាល់ទាន់ពេលវេលា និងទទួលការអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង ០០៤/២។ និង

ង. **អនុញ្ញាត**ឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់សេចក្តីសន្និដ្ឋានដែលបានស្នើសុំ នៅចំពោះមុខ អ.ជ.ត.ក ដោយភ្ជាប់ជាមួយសំណើនេះដើម្បីឱ្យមានប្រសិទ្ធភាព ជាភាសាអង់គ្លេសសិន ចំណែកការបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[41]។

សូម លោក លោកស្រី ចៅក្រមមេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | ជេត វណ្ណលី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | ហុង គីមសួន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | ឡោ ជុនធី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | សំ សុគង់ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | ទី ស្រ៊ីនណា | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | វ៉ែន ពៅ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | Emmanuel JACOMY | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |

[41] *សូមមើល* ឧបសម្ព័ន្ធ ១។ ក្នុងករណីដែលត្រូវបានសម្រេចបែបនេះដោយ អ.ជ.ត.ក មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងដាក់សារណាដូចបានស្នើសុំ ដែលជាឯកសារតែមួយគត់ តាមរយៈប្រព័ន្ធដាក់ឯកសាររបស់ អ.វ.ត.ក រួចជាមួយនឹងតារាងសំអាងឯកសារផ្លូវច្បាប់ ព្រមទាំងឯកសារបកប្រែជាភាសាខ្មែរ នៅពេលបកប្រែរួចរាល់ហើយ។

| | | | |
|---|---|---|---|
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | Martine JACQUIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Me Martine JACQUIN |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | Daniel MCLAUGHLIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២០ | Nushin SARKARATI | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |